# របាយការណ៍

## ស្តីពីការ

## រៀបចំប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ខួបលើកទី៦១

## (១០ ធ្នូ ១៩៤៨ - ១០ ធ្នូ ២០០៩)

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ នៅភូមិគ្រឹះលេខ១៦០អា ផ្លូវ២០១១ ក្រុមទី២ ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៦១ ដែលរៀបចំឡើងដោយអង្គការ សមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជា ហើយសមាសភាពចូលរួម មានព្រះឧបជ្ឈាយ៍មហា យៀង សិន ព្រះចៅអធិការវត្តសាមគ្គីរង្សី និងជាព្រះប្រធានសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម ព្រះតេជគុណ ច័ន្ទ សុផាត ប្រធានសម្ព័ន្ធសមណៈនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម ឯកឧត្តម យត្ត ថាវ្រ សមាជិកសភាមណ្ឌលបន្ទាយមានជ័យ និងជាប្រធានមជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោម ឯកឧត្តម ហូរ វ៉ាន់ អ្នកតំណាងរាស្ត្រមណ្ឌលភ្នំពេញ ឯកឧត្តម យិ វណ្ណដេត អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ឆ្នាំង ឯកឧត្តម នុត រំដួល អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ ឯកឧត្តម ឡុង រី អ្នកតំណាងរាស្ត្រមណ្ឌលក្រចេះ ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ អ្នកតំណាងរាស្ត្រមណ្ឌលកណ្តាល ឯកឧត្តម ថាច់ សេដ្ឋា សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ និងជាប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម ឯកឧត្តម ជាម ច័ន្ទនី អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម លោក ស៊ិន យៀង នាយកប្រតិបត្តិសមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ លោក ប៊ុក កែវ តំណាងមិត្តសមាគមខ្មែរកម្ពុជាក្រោម លោកស្រី ព្រំ យ៉ាង នាយិកាអង្គការស្ត្រីខ្មែរកម្ពុជាក្រោម លោក ធុន សាវ៉ែន មន្ត្រីតស៊ូមតិសមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម លោក គឹម ម៉ៅ តំណាងមូលនិធិខ្មែរសំរាប់អ្នកក្រីក្រ និងបណ្តាសារពត៌មានជាតិ អន្តរជាតិ យ៉ាងច្រើនកុះករ ព្រមទាំងមានការចូលរួមពីបងប្អូនខ្មែរកម្ពុជាក្រោម ប្រមាណជាង៣០០នាក់។

ជាកិច្ចចាប់ផ្តើមនៃកម្មវិធី មានយុវនារីខ្មែរកម្ពុជាក្រោមចំនួន៣រូប បានសូត្របទគោរពទង់ជាតិ និងសូត្របទគោរពវិញ្ញាណក្ខន្ធនៃបុព្វបុរសខ្មែរ ដែលទំលាប់ខ្មែរកម្ពុជាក្រោមតែងតែសូត្រនៅក្នុងពិធីផ្សេងៗ នៅឯដែនដីកម្ពុជាក្រោមកាលពីអតីតកាល។ បន្ទាប់ពីព្រះសង្ឃជយន្តោប្រសិទ្ធិពរជូនអង្គពិធីរួចមក អ្នកបំរើកម្មវិធីបានគោរពអញ្ជើញ ឯកឧត្តម យត្ត ថាវ្រ សមាជិករដ្ឋសភា និងជាប្រធានមជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោម មានមតិសំណេះសំណាល និងប្រកាសបើកកម្មវិធី ដោយឯកឧត្តមលើកយកចំណុចសំខាន់ៗ នៃការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៦១ គឺថ្ងៃទី១០ ធ្នូ ២០០៩ របស់អង្គការសមាគមខ្មែរកម្ពុជាក្រោម ដែលបានប្រារព្ធនៅថ្ងៃថ្លានាឱកាសនេះ។ គោលបំណងរបស់យើងនាថ្ងៃនេះ គឺមាន០៣ចំណុចគឺ ទី១ ដើម្បីបង្ហាញឱ្យពិភពលោកបានឮ បានដឹង បានយល់ អំពីទុក្ខលំបាក និងការរងនូវអំពើរំលោភសិទ្ធិមនុស្ស រំលោភសិទ្ធិជនជាតិដើម និងរំលោភសិទ្ធិសេរីភាពលើគ្រប់វិស័យ ពីសំណាក់អាជ្ញាធរវៀតណាមមកលើប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅដែនដី កម្ពុជាក្រោម (កូសាំងស៊ីន) ហើយពួកគាត់កំពុងតែទ្រហោយហៅឱ្យយើង គេទាំងឡាយជួយដល់ពួកគាត់ផង មានន័យថា បច្ចុប្បន្នកាលនេះបងប្អូនជនរួមឈាមខ្មែរ ដែលកំពុងរស់នៅលើដែនដីកម្ពុជាក្រោម ស្រេកឃ្លានសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពយ៉ាងខ្លាំងក្លាជាទីបំផុត ទី២ គឺវេរចង្ហាន់ប្រគេនព្រះសង្ឃ ដើម្បីធ្វើបង្សុកូលឧទ្ទិសកុសលជូនដល់បុព្វបុរសខ្មែរ និងបរទេស ដែលបានពលីកម្មដោយសារ

ការទាមទារសិទ្ធិសេរីភាពសំរាប់មនុស្សជាតិ ទី៣ គឺពិសារអាហារមិត្តភាពរួមគ្នា ដើម្បីអបអរសាទរថ្ងៃ១០ ធ្នូ ជាទិវាអន្តរជាតិ ដែលខ្មែរកម្ពុជាក្រោមបានរួបរួមគ្នា ប្រារព្ធខួបលើកទី៦១នេះឡើង ហើយឯកឧត្តមបានប្រកាសបើកកម្មវិធីចាប់ពីពេលនេះតទៅ។

នៅក្នុងអង្គពិធីដ៏វិសេសវិសាលនេះ យើងសង្កេតឃើញមានវាគ្មិនជាគណៈអធិបតី ហើយមានចំណាប់អារម្មណ៍ដែលមានរាយនាមដូចតទៅ ឯកឧត្តម យន្ត ថារ៉ូ , លោក ធូន សាវ៉ែន , ឯកឧត្តម ថាច់ សេដ្ឋា , លោក សឺន យឿង , ឯកឧត្តម ហួរ វ៉ាន់, ឯកឧត្តម អ៊ូ ច័ន្ទឫទ្ធិ និងព្រះឧបជ្ឈាយ៍មហា យឿង សិន។ ខ្លឹមសារនៃការចំណាប់អារម្មណ៍ក៏ដូចជា សុន្ទរកថារបស់វាគ្មិនទាំងអស់ គឺផ្តោតអារម្មណ៍ទៅលើទិវាសិទ្ធិមនុស្ស ដ៏និទ្យារិកអធិកអធមនាថ្ងៃនេះ ហើយក៏មិនភ្លេចនូវសេចក្តីត្រូវការ និងស្រេកឃ្លាននៃការរងនូវការរំលោភសិទ្ធិមនុស្ស រំលោភសិទ្ធិជនជាតិដើម និងរំលោភសិទ្ធិសេរីភាពលើគ្រប់វិស័យ ពីសំណាក់អាជ្ញាធរវៀតណាមមកលើជនរួមឈាមខ្មែរកម្ពុជាក្រោម ដូច្នេះអង្គការ សមាគមខ្មែរកម្ពុជាក្រោមទាំងអស់នៅកម្ពុជា បានរៀបចំខួបលើកទី៦១ នៃទិវាសិទ្ធិមនុស្សអន្តរជាតិនេះឡើង គឺចង់បង្ហាញនូវភាពសាមគ្គីគ្នារបស់ខ្មែរកម្ពុជាក្រោម និងចង់ប្រាប់ពិភពលោកឱ្យបានដឹងអំពីទុក្ខសោករបស់ខ្មែរកម្ពុជាក្រោម គ្មានពេលស្រាកស្រាន្ត អញ្ចឹងហើយបញ្ហាខ្មែរកម្ពុជាក្រោម ក៏វានៅក្នុងចំណោមនៃជនរងគ្រោះទាំងនោះដែរ។ ម្ល៉ោះហើយកាលណានិយាយដល់ខ្មែរកម្ពុជាក្រោម វាត្រូវតែពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រ ទៅនឹងមនុស្សជាតិទៅនឹងការរំលោភសិទ្ធិមនុស្ស ទៅនឹងសិទ្ធិជនជាតិដើម ទៅនឹងជំនឿសាសនា ទៅនឹងសិទ្ធិសេរីភាព។ ដោយពិធីនេះមាននិទ្យារិកអធិកអធម ធ្វើឱ្យអ្នកចូលរួមមានការក្តីរំភើប និងមានការសំណូមពរ សូមឱ្យការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិរបស់ខ្មែរកម្ពុជាក្រោម សូមឱ្យមានជាបន្តបន្ទាប់កុំបីអាក់ខានតាឆ្នាំខាងមុខ។ ហើយនៅក្នុងពិធីនេះក៏មានចែកឯកសារដូចជា ផែនទីកម្ពុជាក្រោម ប្រតិទិនខ្មែរកម្ពុជាក្រោម ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម ដល់គណៈអធិបតី និងប្រជាពលរដ្ឋចូលរួមផងដែរ។

ជាចុងបញ្ចប់នៃកម្មវិធី មានធម្មស្សការ សមាទានសីល វេរចង្ហាន់ប្រគេនព្រះសង្ឃ ដារបង្សុកូល ឧទ្ទិសកុសល ដល់បុព្វបុរសខ្មែរ និងបរទេសដែលបានពលីជីវិត ព្រោះតែបុព្វហេតុសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យសេរី និងមានការទទួលទានអាហាររួមគ្នាក្នុងនាមមហាគ្រួសារខ្មែរកម្ពុជាក្រោម ប្រកបដោយភាពស្និទ្ធស្នាលសប្បាយរីករាយយ៉ាងក្រៃលែង ដែលហួសពីការស្មាន ពីព្រោះអ្នកចូលរួមភាគច្រើនជាយុវជន នៃកូនខ្មែរកំណើតកម្ពុជាក្រោម។ ពិធីទិវាសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោមឆ្នាំនេះ ទោះមានឧបសគ្គផ្លាស់ប្តូរទីតាំងក៏ដោយ ក៏មានវិសាលភាពធំធេងណាស់ ដោយមានការអញ្ជើញចូលរួមពីអ្នកតំណាងរាស្ត្រ អង្គការ NGOs និងអាជ្ញាធរដែនដី ព្រមទាំងសារពត៌មានក្នុងនិងក្រៅស្រុក បានផ្សព្វផ្សាយយ៉ាងច្រើនធ្វើឱ្យមានការចាប់អារម្មណ៍ពីមហាជនយ៉ាងខ

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩

អ្នកធ្វើរបាយការណ៍

សេរី ឧត្តរ

ជំនួយការឯកឧត្តម យន្ត ថារ៉ូ






ខ្មែរកម្ពុជាក្រោម
អបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ ខួបលើកទី៦១
(១០ ធ្នូ ១៩៤៨_ ១០ ធ្នូ ២០០៩)


ស្សអន្តរជាតិ ខួបលើកទី៦១
៩៤៨_ ១០ ធ្នូ ២០០៩)